ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
លេខ...

# ប្រកាសរួម
# ស្តីពី
# ការកំណត់តម្លៃសេវាកម្មសម្រាប់ចុះបញ្ជិកា តម្លៃសេវាកម្មសម្រាប់ការធ្វើតេស្តនិងការចេញវិញ្ញាបនបត្រ តម្លៃលើសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា និង តម្លៃទទួលស្គាល់ជាផ្លូវការ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
## និង
## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៩/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៅស៊ូនិងកែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋាន

កសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ. បក ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីអំពីការបង្កើតវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០៧ ស្តីពីការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ
- បានឃើញប្រកាសលេខ ០៨៦ ប្រក.កសក ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៤ ស្តីពីការដាក់ឱ្យប្រើបទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជា
- បានឃើញប្រកាសលេខ ៤០៣ ប្រក.កសក ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី បែបបទ និង នីតិវិធីសម្រាប់ការស្នើសុំ និងការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពយថាប្រភេទកៅស៊ូកម្ពុជា
- បានឃើញប្រកាសលេខ ៤០៤ ប្រក.កសក ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី បែបបទ និង នីតិវិធីនៃការផ្តល់លិខិតទទួលស្គាល់ជាផ្លូវការ និង លិខិតអនុញ្ញាតឱ្យប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ស ម្រេ ច

**ប្រការ ១** : ត្រូវបានអនុញ្ញាតឱ្យវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា អនុវត្តការយកកម្រៃសេវាកម្មសម្រាប់ចុះបញ្ជិកា ឬ ចុះបញ្ជិកាជាថ្មី កម្រៃសេវាកម្មសម្រាប់ការធ្វើតេស្តនិងការចេញវិញ្ញាបនបត្របញ្ជាក់គុណភាពយថាប្រភេទកៅស៊ូកម្ពុជា កម្រៃលើសិទ្ធិប្រើប្រាស់ ឬ សិទ្ធិប្រើប្រាស់ជាថ្មី ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា សម្រាប់រោងចក្រកែច្នៃកៅស៊ូ និងមន្ទីរពិសោធន៍មូលដ្ឋាន និង កម្រៃទទួលស្គាល់ជាផ្លូវការ ឬ ទទួលស្គាល់ជាផ្លូវការជាថ្មី មន្ទីរពិសោធន៍មូលដ្ឋាន ដូចខាងក្រោម :

| ល.រ | ប្រភេទកម្រៃ | ចំនួនទឹកប្រាក់ |
|---|---|---|
| ១ | -កម្រៃសេវាកម្មសម្រាប់ចុះបញ្ជិកា ឬ ចុះបញ្ជិកាជាថ្មី រោងចក្រកែច្នៃកៅស៊ូ ឬ មន្ទីរពិសោធន៍មូលដ្ឋាន : | ៨០០.០០០រៀល |
| ២ | -កម្រៃសេវាកម្មសម្រាប់ធ្វើតេស្ត និង ការចេញវិញ្ញាបនបត្របញ្ជាក់គុណភាពយថាប្រភេទកៅស៊ូកម្ពុជាក្នុងមួយកែសប៉ាឡែត : | ៨៥.០០០រៀល |
| ៣ | -កម្រៃលើសិទ្ធិប្រើប្រាស់ ឬ សិទ្ធិប្រើប្រាស់ជាថ្មី ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា CSR សម្រាប់រោងចក្រកែច្នៃកៅស៊ូ ឬ មន្ទីរពិសោធន៍មូលដ្ឋាន : | ១.៥០០.០០០រៀល |
| ៤ | -កម្រៃទទួលស្គាល់ជាផ្លូវការ ឬ ទទួលស្គាល់ជាផ្លូវការជាថ្មី មន្ទីរពិសោធន៍មូលដ្ឋាន : | ១.៦៥០.០០០រៀល |

**ប្រការ ២ :** ចំណូលដែលប្រមូលបានដូចមានចែងក្នុងប្រការ ១ ខាងលើនេះ ត្រូវបែងចែកដូចខាងក្រោមៈ

-ទឹកប្រាក់ ៥% ត្រូវបង់ចូលថវិការដ្ឋ

-ទឹកប្រាក់ ៩៥% ត្រូវចាត់ចែងអនុវត្តស្របតាមគោលការណ៍ហិរញ្ញវត្ថុ ចំពោះគ្រឹះស្ថានសា ធារណៈរដ្ឋបាល ។

**ប្រការ ៣ :** កំរិតកម្រៃសេវាកម្ម និង កម្រៃ ដូចមានចែងក្នុងប្រការ១ នៃប្រកាសរួមនេះ អាចធ្វើការកែប្រែតាមការចាំបាច់ ។

**ប្រការ ៤ :** ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥ :** អគ្គលេខាធិការ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងអង្គភាពក្រោមឳវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងអង្គភាពក្រោមឳវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ តាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ [illegible] ឆ្នាំ ២០០៨

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

**ច័ន្ទ.សារុន**

**កន្លែងទទួលៈ**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ ៥
- ឯកសារ- កាលប្បវត្តិ